**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ **១១៩** ប្រក.កសក

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ ៤១៥ប្រក.កសក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់នីតិវិធីសម្រាប់ការគ្រប់គ្រងជីកសិកម្ម ដែលត្រូវធ្វើពាណិជ្ជកម្មគ្រប់រូបភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅជានាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពនូវជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម ដែលមានប្រភពចេញពីប្រតិបត្តិការនៃការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការលក់ដុំលក់រាយ ព្រមជាមួយការអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយសម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម ដើម្បីការពារនូវផលប្រយោជន៍របស់អ្នកប្រើប្រាស់ចុងក្រោយ ឬកសិករនៅក្នុងផលិតកម្មកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះជីកសិកម្មគ្រប់ប្រភេទ វត្ថុធាតុដើមសម្រាប់លាយផ្សំជីកសិកម្ម និងគ្រប់ប្រតិបត្តិការពាណិជ្ជកម្ម ព្រមទាំងសកម្មភាពក្រៅគោលបំណងពាណិជ្ជកម្ម ពាក់ព័ន្ធនឹងជីកសិកម្មគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី២
# ការនាំចូលនាំចេញជីកសិកម្ម

**ប្រការ ៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការនាំចូលនាំចេញជីកសិកម្មគ្រប់ប្រភេទ ក្នុងគោលបំណងធ្វើពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្មនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

**ប្រការ ៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំនាំចូលជីកសិកម្មក្រៅគោលបំណងពាណិជ្ជកម្ម សម្រាប់ការប្រើប្រាស់ជាក់លាក់ សម្រាប់តម្រូវការសាធារណៈឬឯកជន ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញ

សំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ តាមការកំណត់នៅក្នុងគំរូពាក្យស្នើសុំនាំចូលជីកសិកម្ម ក្រៅគោលបំណងពាណិជ្ជកម្ម។

ជីកសិកម្មដែលស្នើសុំនាំចូលសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវធ្វើការចុះបញ្ជីដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ប្រការ ៦.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតនាំចូលជីកសិកម្មក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវបំពេញតាមលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- ឯកសារយថាភូតបញ្ជាក់អត្តសញ្ញាណនៃអ្នកស្នើសុំ មានភាពសមស្របតាមគោលបំណងប្រើប្រាស់ និងជានាភាពស្របច្បាប់
- បញ្ជាក់អំពីគោលបំណងប្រើប្រាស់ និងអំណះអំណាងហេតុផលនៃការប្រើប្រាស់ប្រភេទជីកសិកម្មដែលស្នើសុំ
- បញ្ជាក់បរិមាណជីកសិកម្មដែលត្រូវស្នើសុំនាំចូល ស្របតាមគោលបំណងប្រើប្រាស់
- បញ្ជាក់អត្តសញ្ញាណជីកសិកម្មដែលស្នើសុំ និងភ្ជាប់ឯកសារព្រឹត្តិបត្របច្ចេកទេសប្រភពដើមនៃជីកសិកម្មនោះជាចាំបាច់។

## ប្រការ ៧.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតនាំចូលជីកសិកម្ម ដើម្បីធ្វើវិភាគបមាណីយជានា និងធ្វើការសាកល្បងជីវប្រសិទ្ធភាពលើទីវាលពិសោធន៍ ក្នុងគោលបំណងធ្វើការចុះបញ្ជីប្រភេទជីកសិកម្មនោះ ត្រូវស្នើសុំលិខិតអនុញ្ញាតនាំចូលសំណាកជីកសិកម្មជាមុននៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ តាមការកំណត់នៅក្នុងគំរូពាក្យស្នើសុំនាំចូលជីកសិកម្មក្រៅគោលបំណងពាណិជ្ជកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចផ្តល់លិខិតអនុញ្ញាតនាំចូលសំណាកជីកសិកម្មនូវបរិមាណសមស្រប សម្រាប់តែធ្វើវិភាគបមាណីយជានានិងធ្វើការសាកល្បងជីវប្រសិទ្ធភាពលើទីវាលពិសោធន៍ ដើម្បីបង្កើតទិន្នន័យជីវប្រសិទ្ធភាពតាមសំណើសុំការចុះបញ្ជី និងដោយផ្អែកតាមពិធីសារបច្ចេកទេសសាកល្បងជីវប្រសិទ្ធភាពនៃជីកសិកម្ម។

## ប្រការ ៨.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម អាចទទួលលទ្ធផលនៃការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើពាក្យស្នើសុំរបស់ខ្លួន ក្នុង

រយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំនៅនាយកដ្ឋាននីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្មមានសុពលភាពរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

**ប្រការ ៩.-**

ប្រតិបត្តិករនាំចូលជីកសិកម្ម ត្រូវធ្វើប្រតិវេទន៍ជាមុនក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីការនាំចូលមកដល់នៅក្នុងឃ្លាំងអចិន្ត្រៃយ៍របស់ប្រតិបត្តិករ ដើម្បីក្រសួងចាត់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យដើមគ្រា។

ការធ្វើប្រតិវេទន៍លើជីកសិកម្មនាំចេញ ត្រូវអនុវត្តនៅពេលប្រតិបត្តិករដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញជីកសិកម្ម។ រយៈពេលនៃការត្រួតពិនិត្យដើមគ្រាសម្រាប់ជីកសិកម្មនាំចេញ មិនត្រូវបានរាប់បញ្ចូលក្នុងដំណើរការពិនិត្យសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើការស្នើសុំនាំចេញជីកសិកម្មនោះឡើយ។

ជីកសិកម្មដែលធ្វើប្រតិវេទន៍នៅពេលធ្វើការនាំចូលឬធ្វើការនាំចេញ ត្រូវដកយកសំណាកដើម្បីធ្វើវិភាគបមាណីយជានា និងធ្វើការត្រួតពិនិត្យលើការអនុវត្តការតម្រូវបមាណីយនៅមុនពេលផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ ឬនៅមុនពេលធ្វើការនាំចេញ។

**ប្រការ ១០.-**

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី១នៃប្រកាសនេះ។

## ជំពូកទី៣
## ការលាយផ្សំ ការវេចខ្ចប់ជាថ្មី និងការធ្វើសន្និធិជីកសិកម្ម

**ប្រការ ១១.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីនូវជីកសិកម្មគ្រប់ប្រភេទ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មី នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

ដំណើរការលាយផ្សំឬដំណើរការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវបានត្រួតពិនិត្យនិងវាយតម្លៃជាមុនដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការផ្តល់លិខិតអនុញ្ញាត។ របាយការណ៍នៃដំណើរការលាយផ្សំ ឬវេចខ្ចប់ជាថ្មី

និងសមាសធាតុផ្សំជីកសិកម្ម ត្រូវមានភ្ជាប់ជាចាំបាច់ជាមួយសំណុំឯកសារនៃពាក្យស្នើសុំរបស់ប្រតិបត្តិករ។

**ប្រការ ១២.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម អាចទទួលលទ្ធផលនៃការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើពាក្យស្នើសុំរបស់ខ្លួន ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមិនរួមបញ្ចូលរយៈពេលនៃការត្រួតពិនិត្យនិងវាយតម្លៃលើដំណើរការលាយផ្សំឬវេចខ្ចប់ជាថ្មីនូវជីកសិកម្មនោះឡើយ។

**ប្រការ ១៣.-**

លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម មានសុពលភាពរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ក្នុងរយៈពេល៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព។ ក្នុងករណីខកខានក្នុងការស្នើសុំជាថ្មី លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្មនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

**ប្រការ ១៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវធ្វើប្រតិវេទន៍ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល២(ពីរ)លើកក្នុងមួយឆ្នាំ ឬនៅពេលស្នើសុំនាំចេញ អំពីផលិតផលជីកសិកម្មដែលចេញពីប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនៅឃ្លាំងសន្និធិអចិន្ត្រៃយ៍របស់ក្រុមហ៊ុន ដើម្បីក្រសួងចាត់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យលើការអនុវត្តការតម្រូវបមាណីយជីកសិកម្ម និងត្រូវដកយកសំណាកដើម្បីធ្វើវិភាគបមាណីយជានា នៅមុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ ឬធ្វើការនាំចេញ។

**ប្រការ ១៥.-**

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី២នៃប្រកាសនេះ។

**ប្រការ ១៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើសន្និធិជីកសិកម្មដើម្បីបម្រើឲ្យប្រតិបត្តិការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការផ្គត់ផ្គង់ចែកចាយ ក្នុងគោលបំណងពាណិជ្ជកម្ម ឬសម្រាប់ប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

ឃ្លាំងសន្និធិជីកសិកម្ម ត្រូវបានត្រួតពិនិត្យនិងវាយតម្លៃដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការចុះបញ្ជី។

**ប្រការ ១៧.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំវិញ្ញាបនបត្រចុះបញ្ជីឬចុះបញ្ជីជាថ្មី នូវឃ្លាំងសន្និធិជីកសិកម្មសម្រាប់គោលបំណងពាណិជ្ជកម្ម ឬក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវបង់កម្រៃសេវាកម្មចូលថវិកាជាតិជាមុន ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម អាចទទួលលទ្ធផលនៃការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើពាក្យស្នើសុំរបស់ខ្លួនក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមិនរួមបញ្ចូលរយៈពេលនៃការត្រួតពិនិត្យនិងវាយតម្លៃលើប្រតិបត្តិការសន្និធិនិងទីតាំងឃ្លាំងសន្និធិឡើយ។

**ប្រការ ១៨.-**

វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិ មានសុពលភាពក្នុងរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្រ លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវស្នើសុំជាថ្មី នូវវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិក្នុងរយៈពេល ៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព។ ក្នុងករណីខកខានក្នុងការស្នើសុំជាថ្មី វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិនោះ ត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

**ប្រការ ១៩.-**

គំរូសំណុំបែបបទសម្រាប់ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៣នៃប្រកាសនេះ។

# ជំពូកទី៤
# ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូន

## ប្រការ ២០.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់លិខិតអនុញ្ញាតនាំចូលនាំចេញ លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ និងលិខិតអនុញ្ញាតប្រតិបត្តិការវេចខ្ចប់ជាថ្មីនូវជីកសិកម្មគ្រប់ប្រភេទ ដើម្បីធ្វើការផ្គត់ផ្គង់ចែកចាយដោយផ្ទាល់ដល់សាខារបស់ខ្លួន គ្រឹះស្ថានលក់ដុំលក់រាយ ឬដល់គោលដៅប្រើប្រាស់ផ្សេងទៀតដែលស្ថិតនៅតាមបណ្តាខេត្ត រាជធានីក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើការផ្គត់ផ្គង់ចែកចាយបន្តនូវជីកសិកម្ម នៅតាមបណ្តាខេត្ត រាជធានីក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយទទួលយកជីកសិកម្មពីប្រភពដើមរបស់ក្រុមហ៊ុនដែលធ្វើការនាំចូល ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ដែលកាន់កាប់លិខិតអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវមានកិច្ចសន្យាធ្វើជាអ្នកផ្គត់ផ្គង់ចែកចាយរបស់ក្រុមហ៊ុនដើម និងត្រូវស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

## ប្រការ ២១.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម អាចទទួលលទ្ធផលនៃការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើពាក្យស្នើសុំរបស់ខ្លួនក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ប្រការ ២២.-

លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មមានសុពលភាពរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ នៅមុនពេលផុតសុពលភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម ក្នុងរយៈពេល៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព។ ករណីខកខានក្នុងការស្នើសុំជាថ្មី លិខិតអនុញ្ញាតនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

## ប្រការ ២៣.-

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៤នៃប្រកាសនេះ។

## ប្រការ ២៤.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើការលក់ដុំលក់រាយជីកសិកម្មនៅក្នុងដែនរាជធានី ខេត្តនីមួយៗ ត្រូវស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្មនៅមន្ទីរកសិកម្មរាជធានី ខេត្តសាមី ដោយត្រូវបំពេញសំណុំឯកសារឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ព្រមទាំងត្រូវភ្ជាប់ឯកសារដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ។

ក្នុងករណីក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្តណាមួយដែលបានទទួលប្រតិភូកម្មអំណាច ដោយអនុលោមតាមប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើការលក់ដុំលក់រាយជីកសិកម្ម ត្រូវស្នើសុំលិខិតអនុញ្ញាតនៅការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌសាមីនោះ។

## ប្រការ ២៥.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម អាចទទួលលទ្ធផលនៃការសម្រេចរបស់ប្រធានមន្ទីរកសិកម្មរាជធានី ខេត្តសាមី ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំដោយមន្ទីរកសិកម្ម។

## ប្រការ ២៦.-

លិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្មមានសុពលភាពរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម ក្នុងរយៈពេល៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព។ ករណីខកខានក្នុងការស្នើសុំជាថ្មី លិខិតអនុញ្ញាតនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

## ប្រការ ២៧.-

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៥នៃប្រកាសនេះ។

**ប្រការ ២៨.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលដឹកជញ្ជូនជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានត្រួតពិនិត្យដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការអនុវត្តបទបញ្ជាដូចខាងក្រោម៖

១- ត្រូវប្រើមធ្យោបាយដឹកជញ្ជូនឬមធ្យោបាយផ្ទុកជីកសិកម្ម ដោយធានាបាននូវសុវត្ថិភាពក្នុងការដឹកជញ្ជូន ជៀសវាងការធ្លុះធ្លាយសម្ភារវេចខ្ចប់ឬមធ្យោបាយផ្ទុក និងរក្សាបាននូវបមាណីយគុណភាពដើមនៃជីកសិកម្ម។

២- សម្រាប់គោលបំណងនាំចូលនាំចេញ ត្រូវមានលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម ដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣- សម្រាប់គោលបំណងផ្គត់ផ្គង់ចែកចាយ ត្រូវមានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម និងឯកសារពាក់ព័ន្ធដែលកំណត់ច្បាស់លាស់នូវប្រភព ប្រភេទ បរិមាណនៃជីកសិកម្ម និងទីតាំងឬគ្រឹះស្ថានដែលទទួលយកការផ្គត់ផ្គង់ចែកចាយ។

**ប្រការ ២៩.-**

ត្រូវបានហាមឃាត់ការដឹកជញ្ជូនជីកសិកម្ម ដើម្បីចល័តលក់ដោយផ្ទាល់នៅគ្រប់ទីកន្លែងដល់អ្នកប្រើប្រាស់ចុងក្រោយដោយគ្មានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយ ទោះក្នុងរូបភាពផ្សាយពាណិជ្ជកម្ម ការលក់បណ្តាក់ ការដោះដូរ ឬការធ្វើអំណោយក្តី ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

**ប្រការ ៣០.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវគ្រប់គ្រងចរាចរណ៍លើទីផ្សារ និងការបោះចោលនូវជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ជីកសិកម្មហួសសុពលភាពប្រើប្រាស់ ព្រមទាំងសំណល់ជីកសិកម្មនិងសំបកវេចខ្ចប់ជីកសិកម្ម ដោយត្រូវដាក់បទបញ្ជាដល់ពាណិជ្ជករជីកសិកម្មឲ្យទទួលខុសត្រូវដូចខាងក្រោម៖

- ត្រូវធ្វើសន្និធិដាច់ដោយឡែកនូវជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ជីកសិកម្មហួសសុពលភាពប្រើប្រាស់ដោយដាក់សញ្ញាខ្វែង(×)សម្គាល់លើសំបកវេចខ្ចប់ឬលើមធ្យោបាយផ្ទុកនូវអក្សរពណ៌ក្រហម៖ "**ជីកសិកម្មខូចគុណភាព**" ឬ "**ជីកសិកម្មក្រៅបមាណីយ**" ឬ "**ជីកសិកម្មហួសសុពលភាពប្រើប្រាស់**"
- ត្រូវកត់ត្រាព័ត៌មានអំពីជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ជីកសិកម្មហួសសុពលភាពប្រើប្រាស់ នៅក្នុងសៀវភៅកំណត់ត្រាពាណិជ្ជកម្មរបស់ខ្លួន និងត្រូវរាយការណ៍ជូនមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីស្នើសុំវិធានការបច្ចេកទេស។

**ប្រការ ៣១.-**

ត្រូវហាមឃាត់ការធ្វើពាណិជ្ជកម្មគ្រប់រូបភាព ឬចរាចរណ៍លើទីផ្សារ ការបោះចោលក្នុងទីសាធារណៈ ឬទីកន្លែងផ្សេងទៀត នូវជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ឬជីកសិកម្មហួសសុពលភាពប្រើប្រាស់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់ជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ឬជីកសិកម្មហួសសុពលភាពប្រើប្រាស់ អាចស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីលក់សម្រាប់ឲ្យតែចំពោះរោងចក្រផលិតលាយជីកសិកម្ម សម្រាប់ការប្រើប្រាស់ពិសេស កសិដ្ឋានស្រាវជ្រាវ ឬវិទ្យាស្ថានស្រាវជ្រាវរបស់រដ្ឋ។

**ប្រការ ៣២.-**

ជីកសិកម្មខូចគុណភាព ជីកសិកម្មក្រៅបមាណីយ ជីកសិកម្មហួសសុពលភាពប្រើប្រាស់ ជីកសិកម្មក្លែងបមាណីយ ជីកសិកម្មលាយផ្សំដោយគ្មានមូលដ្ឋានបច្ចេកទេស ជីកសិកម្មមានប្រភពដើមល្មើសច្បាប់ ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មគ្រប់រូបភាព ឬធ្វើចរាចរណ៍លើទីផ្សារដោយល្មើសច្បាប់ ត្រូវឃាត់ទុកជាបណ្តោះអាសន្នដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដោះស្រាយតាមនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

## ជំពូកទី៥
## ការផ្សាយពាណិជ្ជកម្មជីកសិកម្ម

**ប្រការ ៣៣.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើការផ្សាយពាណិជ្ជកម្មជីកសិកម្ម ត្រូវស្នើសុំការចុះបញ្ជីប្រភេទជីកសិកម្មនោះជាមុន ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

អត្ថបទផ្សព្វផ្សាយ ឯកសារបោះពុម្ព រូបភាពសោតទស្សន៍ បទបង្ហាញ មេរៀនណែនាំបច្ចេកទេសសម្រាប់សិក្ខាសាលាផ្សព្វផ្សាយ ឯកសារបច្ចេកទេសសម្រាប់ពិសោធន៍លើស្រែបង្ហាញ ឬលើទីវាលពិសោធន៍ ឬឯកសារផ្សេងទៀតសម្រាប់ការផ្សាយពាណិជ្ជកម្មជីកសិកម្មគ្រប់ប្រភេទ ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៣៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវដាក់ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយឬការផ្សាយពាណិជ្ជកម្មជីកសិកម្ម នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងរយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ នៅមុនកាលបរិច្ឆេទអនុវត្តការផ្សព្វផ្សាយឬការផ្សាយពាណិជ្ជកម្ម។

ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយឬការផ្សាយពាណិជ្ជកម្មជីកសិកម្ម ត្រូវភ្ជាប់ជាមួយនូវកម្មវិធីផ្សព្វផ្សាយប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលបញ្ជាក់នូវកាលបរិច្ឆេទនិងទីកន្លែងដែលត្រូវធ្វើការផ្សព្វផ្សាយ

ការផ្សាយពាណិជ្ជកម្ម សិក្ខាសាលា ឬការធ្វើស្រែបង្ហាញ។ល។ រួមជាមួយអត្ថបទ ឬឯកសារបច្ចេកទេស ដែលត្រូវប្រើប្រាស់ក្នុងការផ្សព្វផ្សាយ ដើម្បីអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការពិនិត្យ សិក្សា ឬធ្វើការកែតម្រូវតាមការចាំបាច់ ស្របតាមទិដ្ឋភាពបច្ចេកទេស។

## ប្រការ ៣៥.–

អត្ថបទផ្សាយពាណិជ្ជកម្មជីកសិកម្មត្រូវមានខ្លឹមសារបច្ចេកទេសស្របតាមខ្លឹមសារបច្ចេកទេស ដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវអនុលោមតាមព័ត៌មានឬទិន្នន័យ ដែលកំណត់ក្នុងស្លាកសញ្ញាព័ត៌មាន ឬតាមឯកសារបច្ចេកទេសនៃផលិតផលជីកសិកម្មដែលបានភ្ជាប់ និងបានអះអាងនៅក្នុងពេលធ្វើការចុះបញ្ជី។

អត្ថបទផ្សាយពាណិជ្ជកម្មជីកសិកម្មអាចអធិប្បាយក្នុងក្របខ័ណ្ឌដូចខាងក្រោម៖

- អត្តសញ្ញាណប្រភេទជីកសិកម្មរួមមាន ឈ្មោះពាណិជ្ជកម្ម ពាណិជ្ជសញ្ញា ឈ្មោះសារជាតុចិញ្ចឹម និងទម្រង់រូបសាស្ត្រ

- អត្តសញ្ញាណក្រុមហ៊ុនកាន់កាប់បញ្ជិកា លេខបញ្ជិកា ប្រទេសនិងក្រុមហ៊ុនប្រភពដើមនៃការលាយផ្សំ ការនាំចូល ការផ្គត់ផ្គង់ចែកចាយ

- របៀបប្រើប្រាស់រួមមាន ប្រភេទដំណាំគោលដៅ តំបន់ដាំដុះ បរិមាណ ពេលវេលាប្រើប្រាស់ ចំនួនលើកប្រើប្រាស់

- ប្រសិទ្ធភាពរបស់ផលិតផលជីកសិកម្មរួមមាន កំណើនទិន្នផល រយៈពេល និងរូបមន្តប្រើប្រាស់ជីកសិកម្មដែលផ្តល់កំណើនទិន្នផល

- ណែនាំអតិថិជនឲ្យអានសេចក្តីណែនាំនៅក្នុងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ មុននឹងធ្វើការប្រើប្រាស់។

## ប្រការ ៣៦.–

ការផ្សាយពាណិជ្ជកម្មជីកសិកម្មត្រូវគោរពតាមវិធាន បទជៀសវាង និងបទហាមឃាត់សម្រាប់ការផ្សាយពាណិជ្ជកម្មជីកសិកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

## ប្រការ ៣៧.–

បន្ទាប់ពីបានទទួលសេចក្តីយល់ព្រមលើអត្ថបទផ្សព្វផ្សាយឬអត្ថបទផ្សាយពាណិជ្ជកម្មជីកសិកម្មរួចហើយ រូបវន្តបុគ្គលឬនីតិបុគ្គល មានសិទ្ធិធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ និងអនុវត្តកម្មវិធីផ្សព្វផ្សាយឬការផ្សាយពាណិជ្ជកម្មផលិតផលជីកសិកម្មរបស់ខ្លួននៅរាជធានី ខេត្ត ដោយត្រូវជូនព័ត៌មានដល់មន្ទីរកសិកម្មសាមី ដើម្បីស្នើសុំកិច្ចសហការ។

# ជំពូកទី៦
# វិធានរួមនិងភាតព្វកិច្ចពាណិជ្ជករជីកសិកម្ម

## ប្រការ ៣៨.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតឬវិញ្ញាបនបត្រនៅក្នុងប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្មគ្រប់រូបភាព ត្រូវបំពេញលក្ខណវិនិច្ឆ័យដូចខាងក្រោមៈ

- ត្រូវបំពេញសំណុំបែបបទស្នើសុំឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ស្របតាមការតម្រូវនៅក្នុងគំរូពាក្យស្នើសុំ
- ត្រូវមានសមត្ថភាពក្នុងការធ្វើប្រតិបត្តិការដែលពាក់ព័ន្ធនឹងការស្នើសុំរបស់ខ្លួន ដោយអនុលោមតាមរបាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តរបស់ប្រតិបត្តិករនៅក្នុងឆ្នាំកន្លងមក
- ត្រូវអនុវត្តកិច្ចប្រតិបត្តិល្អក្នុងការអនុវត្តច្បាប់ ការអនុវត្តការតម្រូវបមាណីយ បទបញ្ជានិងនីតិវិធីផ្សេងទៀត នៅក្នុងប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្មរបស់ខ្លួន
- មិនធ្លាប់បានទទួលទណ្ឌកម្មព្យួរឬដកហូតលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ ឬធ្លាប់បានទទួលទោសព្រហ្មទណ្ឌណាមួយនៅក្នុងប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្ម នៅក្នុងរយៈពេល២(ពីរ) ឆ្នាំចុងក្រោយ នៅមុនពេលស្នើសុំលិខិតអនុញ្ញាតឬវិញ្ញាបនបត្រថ្មី។

## ប្រការ ៣៩.-

ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការនាំចូលនាំចេញ លាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិ ឬធ្វើការផ្គត់ផ្គង់ចែកចាយជីកសិកម្មគ្រប់ប្រភេទ ត្រូវដាក់តាំងបង្ហាញនៅក្នុងគ្រឹះស្ថានរបស់ខ្លួននូវលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រដែលពាក់ព័ន្ធ និងត្រូវតម្កល់ឯកសារវិញ្ញាបនបត្របញ្ជាក់បញ្ជិកាប្រភេទជីកសិកម្មដែលកំពុងធ្វើប្រតិបត្តិការពាណិជ្ជកម្ម។

ពាណិជ្ជករលក់ដុំលក់រាយជីកសិកម្មត្រូវតាំងបង្ហាញក្នុងគ្រឹះស្ថានរបស់ខ្លួននូវលិខិតអនុញ្ញាតលក់ដុំលក់រាយ និងត្រូវតម្កល់ឯកសារវិញ្ញាបនបត្របញ្ជាក់បញ្ជិកាប្រភេទជីកសិកម្ម ឬបញ្ជីជីកសិកម្មដែលមានបញ្ជាក់លេខបញ្ជិកា។

## ប្រការ ៤០.-

គ្រប់គ្រឹះស្ថានដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្ម ត្រូវមាន**សៀវភៅកំណត់ត្រាពាណិជ្ជកម្ម**តាមគំរូរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវចុះក្នុងសៀវភៅនោះ អំពីប្រភេទយថាប្រភេទ បរិមាណជីកសិកម្មដែលធ្វើពាណិជ្ជកម្មប្រចាំឆ្នាំ និងកំណត់ត្រាព័ត៌មានចាំបាច់ផ្សេងទៀត។

ពាណិជ្ជករជីកសិកម្មត្រូវរាយការណ៍ ឬផ្តល់ព័ត៌មានជូនមន្ត្រីឬអង្គភាពកសិកម្មមានសមត្ថកិច្ចនៅក្នុងមូលដ្ឋានសាមី ក្នុងករណីសង្ស័យចំពោះអ្នកទិញជីកសិកម្មណាមួយយកទៅកែច្នៃឬផលិតជាគ្រឿងផ្ទុះក្រៅគោលបំណងកសិកម្ម ដែលអាចបង្កផលប៉ះពាល់ដល់សន្តិសុខជាតិ។

## ប្រការ ៤១.-

ពាណិជ្ជករជីកសិកម្មដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មគ្រប់រូបភាព ត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវរក្សាសៀវភៅកំណត់ត្រាពាណិជ្ជកម្ម ឯកសារសក្ខីបត្រ វិក្កយបត្រ និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួននៅក្នុងរយៈពេលយ៉ាងតិច២(ពីរ)ឆ្នាំក្រោយប្រតិបត្តិការទាំងនោះបានបញ្ចប់
- ត្រូវគ្រប់គ្រងជីកសិកម្មដែលធ្វើសន្និធិសម្រាប់លក់ឲ្យបានសមស្របតាមលក្ខណបច្ចេកទេស និងធានាឲ្យឃ្លាំងសន្និធិជីកសិកម្មមានសុវត្ថិភាព ដោយត្រូវអនុវត្តការតម្រូវបមាណីយសម្រាប់ការធ្វើសន្និធិឬសម្រាប់ការដាក់តាំងលក់ជីកសិកម្ម
- ត្រូវបំពាក់ស្លាកសញ្ញាសុវត្ថិភាព ឧបករណ៍ការពារសុវត្ថិភាព ឧបករណ៍លាងសម្អាត សម្ភារអនាម័យ សម្ភារលុបបំបាត់ការលេចជ្រាប ប្រព័ន្ធការពារអគ្គីភ័យ និងប្រព័ន្ធការពារសុវត្ថិភាពផ្សេងទៀតនៅក្នុងគ្រឹះស្ថានធ្វើប្រតិបត្តិការរបស់ខ្លួន
- ត្រូវមានមធ្យោបាយសម្រាប់ផ្ទុកឬសន្និធិជីកសិកម្មដែលធានាមិនធ្លុះធ្លាយ មិនលេចជ្រាប ឬបាត់បង់គុណភាពនៅក្នុងការធ្វើសន្និធិ ការដឹកជញ្ជូន ការលើកដាក់ ឬក្នុងប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន
- ត្រូវអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីវិធានសុវត្ថិភាពក្នុងគ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធ និងបំពាក់ឧបករណ៍ការពារសុវត្ថិភាពដល់បុគ្គលិកប្រតិបត្តិការដោយផ្ទាល់
- ត្រូវកំណត់និងអនុវត្តបទដ្ឋានបច្ចេកទេសសម្រាប់ប្រើប្រាស់និងថែទាំឧបករណ៍ដែលប្រើប្រាស់ជាមួយជីកសិកម្ម និងឧបករណ៍ការពារសុវត្ថិភាព
- ត្រូវអនុវត្តកម្មវិធីត្រួតពិនិត្យនិងថែទាំសុខភាពជាប្រចាំដល់បុគ្គលិកប្រតិបត្តិការផ្ទាល់ជាមួយជីកសិកម្ម។

## ប្រការ ៤២.-

ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការនាំចូល លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវជីកសិកម្ម អាចធ្វើការផ្គត់ផ្គង់ចែកចាយជីកសិកម្មចំពោះតែគ្រឹះស្ថានលក់ដុំលក់រាយឬសាខាចំណុះរបស់ខ្លួន ដែលកាន់កាប់លិខិតអនុញ្ញាតលក់ដុំលក់រាយស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនិងនីតិវិធីនៃប្រកាសនេះប៉ុណ្ណោះ។

ក្រុមហ៊ុនដែលធ្វើការផ្គត់ផ្គង់ចែកចាយ ឬផ្គត់ផ្គង់ចែកចាយបន្តនូវជីកសិកម្ម ត្រូវទទួលខុសត្រូវលើប្រតិបត្តិការពាណិជ្ជកម្មរបស់សាខាខ្លួនឬគ្រឹះស្ថានលក់ដុំលក់រាយទាំងឡាយណា ដែលបានចុះកិច្ចសន្យានិងទទួលយកការផ្គត់ផ្គង់ចែកចាយជីកសិកម្មរបស់ខ្លួន។

ក្រុមហ៊ុនដែលផ្គត់ផ្គង់ចែកចាយបន្ត គ្រឹះស្ថានលក់ដុំលក់រាយ និងកសិដ្ឋានដែលកាន់កាប់និងប្រើប្រាស់ជីកសិកម្ម ត្រូវទទួលយកការផ្គត់ផ្គង់ចែកចាយ ឬត្រូវទិញចូលសម្រាប់បម្រើប្រតិបត្តិការ

របស់ខ្លួននូវជីកសិកម្មដែលមានប្រភពស្របច្បាប់ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងនីតិវិធីនៃប្រកាសនេះ។

## ប្រការ ៤៣.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់បញ្ជិកាជីកសិកម្មគ្រប់ប្រភេទ មានកាតព្វកិច្ចធ្វើការសាកល្បងជីវប្រសិទ្ធភាពលើផលិតផលជីកសិកម្មរបស់ខ្លួនឡើងវិញ នៅក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំម្តង គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកាដំបូង ដោយអនុលោមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម។

## ប្រការ ៤៤.-

ពាណិជ្ជករដែលធ្វើការផ្គត់ផ្គង់ចែកចាយ ឬធ្វើការលក់ដុំលក់រាយជីកសិកម្ម ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈជាមុន ដើម្បីបំពេញបុរេលក្ខខណ្ឌសម្រាប់ការស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយ ឬលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម។

ពាណិជ្ជករដែលធ្វើការផ្គត់ផ្គង់ចែកចាយបន្ត ឬធ្វើការលក់ដុំលក់រាយជីកសិកម្ម ត្រូវដាក់ពាក្យស្នើសុំឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់ការធ្វើប្រតិបត្តិការរបស់ខ្លួន នៅមន្ទីរកសិកម្មរាជធានី ខេត្តសាមី។

## ប្រការ ៤៥.-

មន្ទីរកសិកម្មរាជធានី ខេត្ត ដោយសហការនិងសម្របសម្រួលជាមួយនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចរៀបចំកម្មវិធី លើកគម្រោងបើកវគ្គ និងផ្តល់សេវាកម្មក្នុងការអនុវត្តកម្មវិធីអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់ការធ្វើពាណិជ្ជកម្មជីកសិកម្ម នៅតាមរាជធានី ខេត្តសាមី។

គោលការណ៍ណែនាំសម្រាប់ដំណើរការវគ្គអប់រំនិងកម្មវិធីអប់រំសមត្ថភាពវិជ្ជាជីវៈ សម្រាប់ការធ្វើពាណិជ្ជកម្មជីកសិកម្ម ត្រូវកំណត់ដោយនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ប្រការ ៤៦.-

ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការនាំចូលនាំចេញ លាយផ្សំ និងវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវមានបុគ្គលិកបច្ចេកទេសប្រចាំការមួយរូបឬច្រើនរូប ដើម្បីទទួលខុសត្រូវជាអចិន្ត្រៃយ៍លើក្របខ័ណ្ឌបច្ចេកទេសក្នុងប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន និងត្រូវមានការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធី នៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

ក្រុមហ៊ុនដែលស្នើសុំធ្វើការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មីនូវជីកសិកម្ម ត្រូវភ្ជាប់ជាមួយពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន នូវវិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកបច្ចេកទេសប្រចាំការ។ ក្រុមហ៊ុនត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងករណីមានការបញ្ឈប់ ឬផ្លាស់ប្តូរបុគ្គលិកបច្ចេកទេសដើម្បីស្នើសុំការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកថ្មី។

ការស្នើសុំការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកបច្ចេកទេសប្រចាំការ និងការស្នើសុំឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់អ្នកផ្គត់ផ្គង់ចែកចាយបន្ត អ្នកលក់ដុំលក់រាយជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

### ប្រការ ៤៧.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្មគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលខុសត្រូវចំពោះជីកសិកម្មដែលដាក់តាំងលក់ឬធ្វើសន្និធិសម្រាប់លក់នៅក្នុងគ្រឹះស្ថានពាណិជ្ជកម្មឬឃ្លាំងសន្និធិរបស់ខ្លួន ដោយត្រូវគោរពនិងអនុវត្តតាមបទប្បញ្ញត្តិ និងបទហាមឃាត់ក្នុងសកម្មភាពពាណិជ្ជកម្មជីកសិកម្ម ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងត្រូវធ្វើសហការ បង្កលក្ខណៈងាយស្រួលដល់គ្រប់សកម្មភាពអប់រំណែនាំ ត្រួតពិនិត្យនិងអនុវត្តច្បាប់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### ប្រការ ៤៨.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសឬមិនគោរពតាមនីតិវិធីនិងបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មដាក់លាក់ដោយអនុលោមតាមទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

# ជំពូកទី៨
# អវសានប្បញ្ញត្តិ

**ប្រការ ៤៩.-**

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៥០.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្មរាជធានីខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

ច័ន្ទ. សារុន

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-គ្រប់សាលារាជធានី ខេត្ត
-ដូចប្រការ ៥០
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ពន្ធទី១ នៃប្រកាស លេខ១១៩ប្រក.កសក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣
ស្តីពី"**នីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម**"

# គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្ម

## ក-គំរូពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលនាំចេញជីកសិកម្មក្នុងគោលបំណងពាណិជ្ជកម្ម

| | |
|---|---|
| **I-ព័ត៌មានទូទៅស្តីពីអ្នកស្នើសុំ** (General Information on the Applicant) | |
| **១-ឈ្មោះអ្នកស្នើសុំ៖** | |
| **២-សញ្ជាតិ៖** អាយុ៖ ភេទ ៖ | |
| **៣-អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនលេខ៖** ផុតកំណត់ថ្ងៃទី៖ | |
| **៤-ក្រុមហ៊ុនឬនីតិបុគ្គលឯកជន៖** "គូសក្នុងប្រអប់" | |
| ☐ នាំចូលនាំចេញ ☐ ផ្គត់ផ្គង់ចែកចាយ ☐ សហគមន៍កសិកម្ម<br>☐ លាយផ្សំ ☐ វេចខ្ចប់ជាថ្មី<br>☐ នីតិបុគ្គលឯកជនផ្សេងទៀត៖ | |
| **៥-អាសយដ្ឋាននៅកម្ពុជា៖** | |
| ទូរសព្ទឬទូរសារ៖ | |
| គេហទំព័រ៖ | |
| **៦-ចុះបញ្ជីពាណិជ្ជកម្ម៖**<br>**ចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត៖** | |
| **៧-ឃ្លាំងសន្និធិ** | |
| លេខចុះបញ្ជី និងអាសយដ្ឋាន | |
| | |
| | |
| **៨-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ "បើសិនជាមាន"** | |
| **៩-អត្តសញ្ញាណនៃប្រភពដើមលាយផ្សំឬផ្គត់ផ្គង់ចែកចាយ** | |
| ឈ្មោះនិងអាសយដ្ឋាននៃក្រុមហ៊ុនប្រភពដើមផ្គត់ផ្គង់ចែកចាយ | |
| ឈ្មោះនិងអាសយដ្ឋាននៃក្រុមហ៊ុនប្រភពដើមលាយផ្សំ | |

| |
|---|
| **II-គោលបំណងនៃការស្នើសុំ** ( Purpose and state of application ) "គូសក្នុងប្រអប់" |

| | |
|---|---|
| ☐ ការនាំចូល<br>☐ ការនាំចេញ<br>☐ ការផ្គត់ផ្គង់ចែកចាយ | ☐ ការផ្ទេរសិទ្ធិលើលិខិតអនុញ្ញាត<br>☐ គោលបំណងពាណិជ្ជកម្មផ្សេងទៀត |

| |
|---|
| **III-មធ្យោបាយដឹកជញ្ជូន កំពង់ផែ ឬមាត់ច្រកដែលនាំចូលនាំចេញ** ( Mean of transport, port, or border entry to be imported-exported ) "គូសក្នុងប្រអប់" |

| | |
|---|---|
| មធ្យោបាយដឹកជញ្ជូន ៖<br>☐ រថយន្ត<br>☐ នាវា<br>☐ យន្តហោះ<br>☐ មធ្យោបាយផ្សេងទៀត៖............................... | កំពង់ផែឬមាត់ច្រក ៖<br>☐ កំពង់ផែ....................................................<br>..............................................................................<br>☐ មាត់ច្រក..................................................<br>.............................................................................. |

| |
|---|
| **IV-យថាប្រភេទនិងបរិមាណជីកសិកម្មដែលស្នើសុំការនាំចូលនាំចេញ** ( Specification & quantity of fertilizers to be imported/exported ) ☐ មានភ្ជាប់ CD ឬបញ្ជីដោយឡែក ( បើសិនជាច្រើន ) |

| ល.រ No | យថាប្រភេទជីកសិកម្ម Specification | ឈ្មោះពាណិជ្ជកម្ម Trade name | លេខបញ្ជិកា Registration N$^0$ | បរិមាណស្នើនាំចូលនាំចេញ Quantity to be imported/exported | ក្រុមហ៊ុន/ប្រទេសប្រភពដើម Company/Country of origin |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |

សរុបត្រឹមចំនួន៖...................មុខ បរិមាណ៖.............................

| V-**បញ្ជីឯកសារត្រូវភ្ជាប់ជាមួយ** ( List of documents enclosed ) | |
|---|---|
| ១- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ប័ណ្ណប៉ាតង់ ឬប័ណ្ណបង់ពន្ធលើផលរបរ(ITR)នៃឆ្នាំចុងក្រោយ ឬឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គលឯកជនផ្សេងទៀត។ | ០១ច្បាប់ |
| ២- ឯកសារឬកិច្ចសន្យាបញ្ជាក់ការផ្គត់ផ្គង់របស់ក្រុមហ៊ុនប្រភពដើម។ | ០១ច្បាប់ |
| ៣- របាយការណ៍ត្រួតពិនិត្យដើមគ្រានៅពេលស្នើសុំនាំចេញជីកសិកម្ម (ករណីនាំចេញ)។ | ០១ច្បាប់ |
| ៤- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្មតាមយថាប្រភេទនីមួយៗ ដែលត្រូវស្នើសុំនាំចូលនាំចេញ។ | ០១ច្បាប់ |
| ៥- សំបកវេចខ្ចប់ជីកសិកម្មតាមប្រភេទនីមួយៗដែលមានស្លាកសញ្ញាព័ត៌មានឬបរិយាយប័ណ្ណសម្រាប់ការណែនាំជាភាសាខ្មែរដែលបានយល់ព្រមនៅពេលធ្វើការចុះបញ្ជី។ | ០១ច្បាប់ |
| ៦- លិខិតបញ្ជាក់របស់ក្រុមហ៊ុនអំពីអត្តសញ្ញាណបុគ្គលិកបច្ចេកទេសប្រចាំការគ្រឹះស្ថាននាំចូលនាំចេញរបស់ខ្លួន និងដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ | ០១ច្បាប់ |
| ៧- របាយការណ៍អំពីសមត្ថភាពធ្វើប្រតិបត្តិការនាំចូលនាំចេញជីកសិកម្មរបស់ក្រុមហ៊ុននៅក្នុងឆ្នាំចុងក្រោយមុនពេលស្នើសុំ។ | ០១ច្បាប់ |
